**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍ស្តីអំពីការបំពេញទំរង់ពត៌មានអ្នកជំងឺអេដស៍ ដែលបានកែសំរួល និងបន្ថែមថ្មី

Report on Training on New Form Revised for HIV Patients

## នៅមន្ទីរសុខាភិបាលខេត្តពោធិសាត់

ថ្ងៃទី ១៧-១៨ ខែ ធ្នូ ឆ្នាំ ២០១៤

វគ្គបណ្តុះបណ្តាលស្តីអំពីការបំពេញទំរង់ពត៌មានរបស់អ្នកជំងឺអេដស៍ដែលបានកែសំរួល និងបន្ថែមថ្មី បានប្រព្រឹត្តទៅនៅមន្ទីរសុខាភិបាលខេត្តពោធិសាត់ ចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៤, ដែលរៀបចំឡើងដោយផ្នែកគ្រប់គ្រងទិន្នន័យ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ក្រោមការឧបត្ថម្ភថវិកាពីគំរោងមូនិធិសកល (GFATM)។ វគ្គបណ្តុះបណ្តាលនេះ គឺធ្វើឡើងក្នុង គោលបំណងផ្តល់នូវពត៌មានថ្មីៗដែលមជ្ឈមណ្ឌលជាតិបានរៀបចំដាក់អោយប្រើប្រាស់នូវទំរង់ពត៌មានរបស់អ្នកជំងឺដែលបានកែសំរួល និង បន្ថែថ្មី។

វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពី: គ្រូពេទ្យពិនិត្យនិងព្យាបាលជំងឺមនុស្សពេញវ័យ អ្នកជំងឺ កុមារ កុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ មន្ត្រីបញ្ចូលទិន្នន័យ មន្ត្រីគ្រប់គ្រងទិន្នន័យវិធីសាស្ត្រឆ្លើយតបរួមគ្នា និង មន្ត្រីគ្រប់គ្រងទិន្នន័យខេត្ត-ក្រុង ។

<u>គណ:ធិបតី ៖</u>

| | | |
|---|---|---|
| លោកវេជ្ជបណ្ឌិត | អ៊ុក វិជ្ជា | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |

<u>មន្ត្រីសំរបសំរួលវគ្គ និងគ្រូឧទ្ទេសនាម:</u>

| | | |
|---|---|---|
| លោក | ម៉ម សុវត្ថា | អនុប្រធានមជ្ឈមណ្ឌលជាតិ |
| លោកវេជ្ជបណ្ឌិត | សេង សុភាព | ប្រធានការិយាល័យបច្ចេកទេស |
| លោកគ្រូពេទ្យ | ជា ចំណាន | អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យ |
| លោក | ផាត់ វាសនា | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ |
| លោក | លាង សុផាន់ណា | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ |

សកម្មភាពនៃវគ្គបណ្តុះបណ្តាល ៖

ថ្ងៃទី ១ ៖ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៤

ពេលព្រឹក

ចាប់ពីម៉ោង ៨-០០នាទី ដល់ម៉ោង ៨-៣០ ៖ ការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមទាំងអស់, ដែលក្នុងនោះមាន ៖

♦ ខេត្ត កំពង់ស្ពឺ ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យខេត្ត កំពង់ស្ពឺ ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យខេត្ត កំពង់ស្ពឺ ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត ចំនួន០២ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកគងពិសី ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកគងពិសី ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកឧត្តុង្គ ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកឧត្តុង្គ ចំនួន០១ នាក់

♦ ខេត្ត កោះកុង ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យខេត្ត ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យខេត្ត ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត ចំនួន០២ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកស្រែអំបិល ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកស្រែអំបិល ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកស្រែអំបិល ចំនួន០១ នាក់

♦ ខេត្ត កំពង់ឆ្នាំង ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យ កំពង់ឆ្នាំង ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យ កំពង់ឆ្នាំង ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត កំពង់ឆ្នាំង ចំនួន០២ នាក់

♦ ខេត្ត ប៉ៃលិន ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកខេត្ត ប៉ៃលិន ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកខេត្ត ប៉ៃលិន ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត ប៉ៃលិន ចំនួន០២ នាក់

♦ ខេត្ត ព្រះសីហនុ ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យខេត្ត ព្រះសីហនុ ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យខេត្ត ព្រះសីហនុ ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត ព្រះសីហនុ ចំនួន០២ នាក់

♦ ខេត្ត បន្ទាយមានជ័យ ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យសេរីសោភ័ណ ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យសេរីសោភ័ណ ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យសេរីសោភ័ណ ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត បន្ទាយមានជ័យ ចំនួន០២ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យមង្គលបូរី ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកមង្គលបូរី ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យមង្គលបូរី ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកថ្មពួក ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកថ្មពួក ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មណ្ឌលសុខភាពប៉ោយប៉ែត ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មណ្ឌលសុខភាពប៉ោយប៉ែត ចំនួន០១ នាក់

♦ ខេត្ត បាត់ដំបង ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យខេត្តបាត់ដំបង ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យខេត្តបាត់ដំបង ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART ជំងឺពេញវ័យមន្ទីរពេទ្យខេត្ត ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART ជំងឺកុមារមន្ទីរពេទ្យខេត្ត ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្តខេត្តបាត់ដំបង ចំនួន០២ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកមោងឫស្សី ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកមោងឫស្សី ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកមោងឫស្សី ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកសំពៅលូន ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកសំពៅលូន ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកសំពៅលូន ចំនួន០១ នាក់

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកថ្មគោល ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកថ្មគោល ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យបង្អែកថ្មគោល ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យយោធភូមិភាគ៥ ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART មន្ទីរពេទ្យ យោធភូមិភាគ៥ ចំនួន០១ នាក់

♦ ខេត្ត ឧត្តរមានជ័យ ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យបង្អែកសំរោង ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យបង្អែកសំរោង ចំនួន០១ នាក់
- មន្ត្រីគ្រប់គ្រងទិន្នន័យអេដស៍ខេត្ត ឧត្តរមានជ័យ ចំនួន០២ នាក់

♦ រាជធានីភ្នំពេញ ៖

- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺពេញវ័យ មន្ទីរពេទ្យខ្មែរ-សូវៀត ចំនួន០១ នាក់
- គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ មន្ទីរពេទ្យខ្មែរ-សូវៀត ចំនួន០១ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART ជំងឺពេញវ័យ ចំនួន០២ នាក់
- មន្ត្រីបញ្ចូលទិន្នន័យអ្នកជំងឺ Pre-ART/ART ជំងឺកុមារ ចំនួន០១ នាក់

♦ ខេត្ត ពោធិ៍សាត់ ៖

- អ្នកសំរបសំរួលកម្មវិធីអេដស៍ខេត្ត ពោធិ៍សាត់ ចំនួន០១ នាក់

បន្ទាប់ពីការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមរួចមក នៅវេលាម៉ោង ៨-៣០ វគ្គបណ្តុះបណ្តាល បានចាប់ផ្តើមដំណើរការរបស់ខ្លួន។ ជាកិច្ចចាប់ផ្តើម លោកវេជ្ជបណ្ឌិត អ៊ុក វិជ្ជា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានមតិសំណេះសំណាលថ្លែងអំណរគុណទៅកាន់ សិក្ខាកាមទាំងអស់ដែលបានចំណាយពេលបានធ្វើដំណើរមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ដើម្បីទទួលយកនូវចំណេះដឹងបន្ថែមសំរាប់យកទៅអនុវត្តន៍ ការងាររបស់ខ្លួនដែលត្រូវបំពេញដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់មជ្ឈមណ្ឌលជាតិ។ លោកវេជ្ជបណ្ឌិត បានផ្តាំផ្ញើអោយសិក្ខាកាមទាំងអស់ត្រូវធ្វើយ៉ាងណាយកចិត្តទុកដាក់ក្នុងការរៀនសូត្រតាមរយៈការបណ្តុះបណ្តាលនេះ ដើម្បីយកទៅអនុវត្តការងារដែលត្រូវបំពេញនៅតាមខេត្តរៀងៗខ្លួន និងបានប្រកាសបើកវគ្គបណ្តុះបណ្តាល។



បន្ទាប់ពីការប្រកាសបើកវគ្គបណ្តុះបណ្តាលរួចមក វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការការងាររបស់ខ្លួន តាមកម្មវិធី និងពេលវេលាកំណត់ដោយបានចាប់ផ្តើមធ្វើការបង្ហាញពីលទ្ធផលនានាដែលបានអនុវត្តកន្លងមក និង ទិសដៅការងារដែលត្រូវអនុវត្តបន្តលើការងារថែទាំ និងព្យាបាលជំងឺអេដស៍មានជាអាទិ៍ ៖

<u>ពេលព្រឹក</u>

- ការបង្ហាញអំពីគោលបំណងរបស់វគ្គបណ្តុះបណ្តាល ដោយលោកវេជ្ជបណ្ឌិត សេង សុភាព។
- ការបង្ហាញអំពីការបំពេញទំរង់ពត៌មានកែសំរួលនិងបន្ថែមថ្មីរបស់អ្នកជំងឺពេញវ័យ ដោយ លោក ជា ចំណាន ដែលក្នុងនោះមានដូចជា:
    - ទំរង់ពត៌មានរបស់អ្នកជំងឺពេញវ័យពេលមកពិនិត្យជំងឺដំបូង (ក)
    - ទំរង់សំរាប់ធ្វើបច្ចុប្បន្នភាពពត៌មានរបស់អ្នកជំងឺពេញវ័យ (ក១)
    - ទំរង់ពត៌មានរបស់អ្នកជំងឺពេញវ័យពេលមកពិនិត្យជំងឺ (ខ)
    - ទំរង់វាយតំលៃសំរាប់ការជូនដំណឹងនិងស្វែងរកដៃគូ ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍ (Partner Tracing and Testing Initial Assessment Form )
    - ការចុះបញ្ជីរបស់អ្នកជំងឺពេញវ័យ
    - ទំរង់របាយការណ៍របស់អ្នកជំងឺពេញវ័យ Pre-ART និង ART



<u>ពេលរសៀល</u>

- ការបង្ហាញអំពីការបំពេញទំរង់ពត៌មានកែសំរួលនិងបន្ថែមថ្មីរបស់អ្នកជំងឺកុមារ ដោយលោក ផាត់ វាសនា ដែលក្នុងនោះមានដូចជាៈ
    - ទំរង់ពត៌មានរបស់អ្នកជំងឺកុមារពេលមកពិនិត្យជំងឺដំបូង (ក)
    - ទំរង់សំរាប់ធ្វើបច្ចុប្បន្នភាពពត៌មានរបស់អ្នកជំងឺកុមារ (ក១)
    - ទំរង់ពត៌មានរបស់អ្នកជំងឺកុមារពេលមកពិនិត្យជំងឺ (ខ)
    - ការចុះបញ្ជីររបស់អ្នជំងឺកុមារ Pre/ART និង ART
    - ទំរង់របាយការណ៍របស់អ្នកជំងឺកុមារ Pre-ART និង ART



ថ្ងៃទី ២ ៖ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៤

ពេលព្រឹក

- ការបង្ហាញអំពីការបំពេញទំរង់ពត៌មានកែសំរួលនិងបន្ថែមថ្មីរបស់អ្នកជំងឺកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ ដោយលោក ជា ចំណាន ដែលក្នុងនោះមានដូចជា:
  - ទំរង់ពត៌មានរបស់អ្នកជំងឺកុមារប្រឈមនឹងមេរោគអេដស៍ពេលមកពិនិត្យជំងឺដំបូង (ក)
  - ទំរង់ពត៌មានរបស់អ្នកជំងឺកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ពេលមកពិនិត្យជំងឺ (ខ)
  - ទំរង់សង្ខេបរបស់កុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ (គ)
  - ការចុះបញ្ជីរបស់អ្នជំងឺកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍
  - ទំរង់របាយការណ៍របស់អ្នកជំងឺកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍
- ការពិភាក្សាទូទៅអំពីការបំពេញទំរង់ពត៌មានរបស់អ្នកជំងឺកុមារ អ្នកជំងឺពេញវ័យ និងកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ដោយមានការសំរបសំរួលពីក្រុមការងាររបស់មជ្ឈមណ្ឌលជាតិ មានដូចជា លោក ម៉ម សុវត្ថា លោកវេជ្ជបណ្ឌិត សេង សុភាព លោក ប៊ូ វឌ្ឍនៈ លោក លាង សុផាន់ណា មានសំណួរនិងយោបល់មួយចំនួនដូចខាងក្រោម៖
  - ទំរង់ PNTT (ខ១)៖
    - គួរប្រគល់អោយ VCCT ជាអ្នកបំពេញតែម្តងសំរាប់អ្នកជំងឺថ្មី។ ទំរង់នេះត្រូវប្រើសំរាប់អ្នកផ្តល់ប្រឹក្សានៅ OI/ART និង VCCT។
    - នៅពេលរកដៃគូឃើញ គួរផ្តល់ពត៌មានទៅអ្នកណា? ត្រូវផ្តល់ពត៌មានទៅដល់ក្រុមថែទាំតាមផ្ទះដើម្បីអោយជួយហៅដៃគូនោះមកទទួលសេវានៅ VCCT។
    - គួរបន្ថែមជំរើសណាមួយ នៅពេលដែលដៃគូអវិជ្ជមាន ហើយអ្នកជំងឺត្រូវបានឱសថ ART ដោយមិនគិតពី CD4 ។
    - គួរជ្រើសរើសសេវាណាមួយដើម្បីធ្វើការសាកល្បងជាមុនសិន
    - សុំលុបឈ្មោះដៃគូចេញ
  - ទំរង់សំរាប់ធ្វើបច្ចុប្បន្នភាពពត៌មានរបស់អ្នកជំងឺកុមារ (ក១)៖
    - គួរបន្ថែមឈ្មោះ Vaccine អោយអស់តែម្តង BCG, Hepatis .....
    - កែសំរួលឈ្មោះ vaccination មិនទាន់គ្រប់ចំនួន
    - ករណីបំបៅដោះសុទ្ធត្រឹមអាយុប៉ុន្មាន?

- ទំរង់សំរាប់ធ្វើបច្ចុប្បន្នភាពពត៌មានរបស់អ្នកជំងឺកុមារ (ខ១)៖
    - គួរដាក់ឡើងវិញនូវ Viral load CD4 ឡើងវិញដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យពេលអ្នកជំងឺមកជួប
- ការបង្ហាញអំពីការងារបញ្ចូលពត៌មានទៅក្នុងប្រព័ន្ធ Database សំរាប់អ្នកជំងឺកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ ដោយ លោក លាង សុផាន់ណា។

<u>ពេលរសៀល</u>

- ការបង្ហាញអំពីការងារបញ្ចូលពត៌មានទៅក្នុងប្រព័ន្ធ Database សំរាប់អ្នកជំងឺកុមារ ដោយ លោក លាង សុផាន់ណា។
- ការបង្ហាញអំពីការងារបញ្ចូលពត៌មានទៅក្នុងប្រព័ន្ធ Database សំរាប់អ្នកជំងឺពេញវ័យ ដោយ លោក លាង សុផាន់ណា។
- ការពិភាក្សាទូទៅអំពីការបញ្ចូលទិន្នន័យ និងទំរង់របាយការណ៍ ក្នុងប្រព័ន្ធ Database ដើម្បីធ្វើអោយ ទិន្នន័យដែល បានបញ្ចូលទៅក្នុង Database មានគុណភាពល្អ និងត្រឹមត្រូវ។
- ពិភាក្សាលើការងារបំពេញទំរង់ពត៌មានអ្នកជំងឺ-ការចុះបញ្ជីកុមារ-ការរៀបចំទុកដាក់ ឯកសារ និងការអនុវត្តន៍ផ្សេងៗទៀត នៅពេលកុមារមានលទ្ធផលឈាមវិជ្ជមាន ។



- ការសំណូមពរពីក្រុមការងារបញ្ចូលទិន្នន័យ៖
    - បន្ថែមប្រវត្តិឱសថធ្លាប់ប្រើពីមុន
    - ចំពោះអ្នកជំងឺមានផ្ទៃពោះ, របេងនិង IPT សុំបញ្ចេញលេខកូដ
    - ថ្នាំ ជួរទី១ បញ្ឈប់អត់មានមូលហេតុ ប៉ុន្តែជួរទី២មាន
    - សូមដាក់មូលហេតុនៃការលះបង់ការព្យាបាលដោយឱសថ ART សំរាប់អ្នកជំងឺខ្លួនឯង

សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលរយៈពេល ២ថ្ងៃកន្លងមក ឃើញថា គ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺកុមារ-មនុស្សពេញវ័យ មន្ត្រីចុះបញ្ជីមន្ត្រីបញ្ចូលទិន្នន័យ និងមន្ត្រីគ្រប់គ្រងទិន្នន័យទាំងអស់បាន យល់ដឹងបន្ថែមលើការងារ ពិនិត្យនិងព្យាបាល ដែលមជ្ឈមណ្ឌលជាតិ បាននិងកំពុងដាក់អោយប្រើប្រាស់។ តាមរយៈការបង្ហាញរបស់គ្រូសម្របសម្រួលមកពីមជ្ឈមណ្ឌលជាតិ និងការយកចិត្តទុកដាក់របស់សិក្ខាកាម ដែលអាចជួយបង្កើននូវសមត្ថភាពក្នុងការប្រមូល-ពិនិត្យ-ព្យាបាលអ្នកជំងឺកាន់តែមានភាពសុក្រិតថែមទៀត និងបំពេញរបាយការណ៍ប្រចាំត្រីមាសបានត្រឹមត្រូវទាន់ពេលវេលា ។

ការងារដែលត្រូវអនុវត្តបន្ទាប់:

- ចំពោះអ្នកជំងឺថ្មីគឺត្រូវប្រើទំរង់ថ្មីចាប់ពីពេលនេះតទៅ
- ចាប់ផ្តើមប្រើចាប់ពីពេលនេះតទៅ
- បំពេញពត៌មានរបស់អ្នកជំងឺអោយបានគ្រប់គ្រាន់និងត្រឹមត្រូវ
- និងមានការបណ្តុះបណ្តាលការងារបញ្ចូលពត៌មានរបស់អ្នកជំងឺពេល database កែរួច

វគ្គបណ្តុះបណ្តាលនេះ បានបញ្ចប់នៅវេលាម៉ោង ១៧-០០ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ក្រោម បរិយាកាសរីករាយ និងស្និតស្នាលជាទីបំផុត ព្រមទាំងប្រកាសដាក់អោយប្រើប្រាស់ទំរង់ពត៌មានរបស់អ្នកជំងឺដែលបានកែសំរួល និងបន្ថែមថ្មីចាប់ពីពេលនេះតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី 19 ខែធ្នូ ឆ្នាំ ២០១៤

| បានឃើញ និង ឯកភាព | បានពិនិត្យ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | ផ្នែកគ្រប់គ្រងទិន្នន័យ | ផ្នែកគ្រប់គ្រងទិន្នន័យ |
| អនុប្រធាន | | |
| វេជ្ជ.លី ពេញ ស៊ុន | ជា ចំណាន | ផាត់ វាសនា |